# ជំនឿនិងទំនៀមទម្លាប់ ដែលមិនផ្គាប់ព្រះហឫទ័យព្រះ

*តើមានជំនឿនិងទំនៀមទម្លាប់បែបណាខ្លះដែលខុស? (១)*

*តើគ្រីស្ទានគួរជឿថាព្រះគឺជាព្រះត្រីឯកភាពឬ? (២)*

*ហេតុអ្វីក៏គ្រីស្ទានពិតមិនធ្វើបុណ្យណូអែល បុណ្យអ៊ីស្ទើរ៍ ឬបុណ្យថ្ងៃកំណើត? (៣, ៤)*

*តើមនុស្សស្លាប់អាចធ្វើទុក្ខដល់មនុស្សរស់បានទេ? (៥) តើព្រះយេស៊ូបានសោយទិវង្គតលើឈើឆ្កាងឬ? (៦)*

*តើការផ្គាប់ព្រះហឫទ័យព្រះគឺសំខាន់យ៉ាងណា? (៧)*



*ព្រះមិនមែនជាព្រះត្រីឯកភាពទេ*

១. មិនមែនជំនឿនិងទំនៀមទម្លាប់ទាំងអស់សុទ្ធតែអាក្រក់នោះទេ ។ ប៉ុន្តែ ព្រះមិនយល់ព្រមទទួលស្គាល់ទេ បើសិនជាជំនឿនិងទំនៀមទម្លាប់ទាំងនេះ គឺមកពីសាសនាក្លែងក្លាយ ឬក៏ប្រឆាំងនឹងសេចក្ដីបង្រៀនព្រះគម្ពីរ ។—ម៉ាថាយ ១៥:៦

២. *ព្រះត្រីឯកភាព៖* តើព្រះយេហូវ៉ាជាព្រះត្រីឯកភាពឬ—គឺថាមានបីអង្គក្នុងព្រះតែមួយនោះ? គឺមិនមែនទេ! ព្រះយេហូវ៉ាដ៏ជាព្រះវរបិតាគឺជា«ព្រះពិតតែ១» ។ (យ៉ូហាន ១៧:៣; ម៉ាកុស ១២:២៩) ព្រះយេស៊ូគឺជារាជបុត្រាច្បងរបស់ព្រះអង្គ ហើយទ្រង់ស្ថិតនៅក្រោមអំណាចនៃព្រះ ។ (កូរិនថូសទី១ ១១:៣) ព្រះវរបិតាគឺធំជាងរាជបុត្រា ។ (យ៉ូហាន ១៤:២៨) វិញ្ញាណបរិសុទ្ធមិនមែនជាបុគ្គលមួយរូបទេ គឺជាសកម្មពលរបស់ព្រះវិញ ។—លោកុប្បត្តិ ១:២; កិច្ចការ ២:១៨

៣. *បុណ្យណូអែលនិងបុណ្យអ៊ីស្ទើរ៍៖* ព្រះយេស៊ូមិនបានចាប់កំណើតនៅថ្ងៃទី២៥ ខែធ្នូនោះទេ ។ ទ្រង់បានចាប់កំណើតប្រហែលនៅថ្ងៃទី១ ខែតុលា ជាគ្រានៃឆ្នាំដែលពួកអ្នកគង្វាលទុកហ្វូងសត្វចិញ្ចឹមរបស់គេនៅឯវាលខាងក្រៅក្រោលនៅពេលយប់ ។ (លូកា ២:៨-១២) ព្រះយេស៊ូមិនដែលបានបញ្ជាពួកគ្រីស្ទានឲ្យធ្វើបុណ្យនៃកំណើតរបស់ទ្រង់ឡើយ ។ ផ្ទុយទៅវិញ ទ្រង់មានបន្ទូលប្រាប់ពួកសិស្សទ្រង់ឲ្យធ្វើពិធីបុណ្យរំឭកឬចងចាំការសោយទិវង្គតរបស់ទ្រង់ ។ (លូកា ២២:១៩, ២០) បុណ្យណូអែលនិងទំនៀមទម្លាប់បុណ្យនេះគឺមកពីសាសនាក្លែងក្លាយជំនាន់បុរាណ ។ ទំនៀមទម្លាប់បុណ្យអ៊ីស្ទើរ៍ដូចជាការប្រើស៊ុតនិងទន្សាយក៏ដូច្នោះដែរ ។ គ្រីស្ទានជំនាន់ដើមមិនបានធ្វើបុណ្យណូអែលឬបុណ្យអ៊ីស្ទើរ៍ទេ ហើយគ្រីស្ទានពិតសព្វថ្ងៃនេះក៏មិនធ្វើបុណ្យទាំងនេះដែរ ។

៤. *ថ្ងៃកំណើត៖* មានតែពិធីបុណ្យថ្ងៃកំណើតពីរទេដែលរៀបរាប់ក្នុងព្រះគម្ពីរ ដែលធ្វើឡើងដោយអ្នកដែល

មិនថ្វាយបង្គំព្រះយេហូវ៉ា ។ (លោកុប្បត្តិ ៤០:២០-២២; ម៉ាកុស ៦:២១, ២២ ២៤-២៧) គ្រីស្ទានជំនាន់ដើមមិនធ្វើបុណ្យថ្ងៃកំណើតទេ ។ ទំនៀមទម្លាប់នៃការធ្វើបុណ្យថ្ងៃកំណើតគឺមកពីសាសនាក្លែងក្លាយជំនាន់បុរាណ ។ ពួកគ្រីស្ទានពិតឲ្យជំនូនគ្នាហើយសប្បាយកំសាន្តកាយជាមួយគ្នានៅថ្ងៃផ្សេងៗឯទៀតនៃឆ្នាំ ។

៥. *ការខ្លាចដល់មនុស្សស្លាប់៖* មនុស្សស្លាប់មិនអាចធ្វើអ្វីបានឬដឹងយល់អ្វីឡើយ ។ យើងមិនអាចជួយពួកមនុស្សស្លាប់បានទេ ហើយពួកគេក៏មិនអាចធ្វើទុក្ខយើងបានដែរ ។ (ទំនុកដំកើង ១៤៦:៤; សាស្ដា ៩:៥, ១០) ព្រលឹងគឺស្លាប់បាន វាឥតរស់នៅបន្តទៅទៀតឡើយក្រោយពេលបានស្លាប់ហើយនោះ ។ (អេសេគាល ១៨:៤) ប៉ុន្តែ ជួនកាលពួកទេវតាអាក្រក់ដែលហៅថាពួកអារក្ស តាំងខ្លួនធ្វើជាវិញ្ញាណនៃមនុស្សស្លាប់ ។ ទំនៀមទម្លាប់ណាដែលមានទាក់ទងនឹងការខ្លាចដល់ឬការថ្វាយបង្គំមនុស្សស្លាប់ នោះគឺខុសហើយ ។—អេសាយ ៨:១៩

៦. *ឈើឆ្កាង៖* ព្រះយេស៊ូមិនបានសោយទិវង្គតលើឈើឆ្កាងទេ ។ ទ្រង់បានសោយទិវង្គតលើបង្គោលឬសសរ ។ ពាក្យក្រិកដែលបកប្រែជា «ឈើឆ្កាង» នៅក្នុងព្រះគម្ពីរជាច្រើនមានន័យថាជាឈើមួយដើមប៉ុណ្ណោះ ។ សញ្ញាឈើឆ្កាងគឺមកពីសាសនាក្លែងក្លាយជំនាន់បុរាណ ។ ឈើឆ្កាងគឺឥតមានប្រើឬយកមកថ្វាយបង្គំដោយពួកគ្រីស្ទានជំនាន់ដើមឡើយ ។ ដូច្នេះ តើអ្នកគិតថាប្រើឈើឆ្កាងក្នុងការថ្វាយបង្គំគឺជាការត្រឹមត្រូវឬ ?—ចោទិយកថា ៧:២៦; កូរិនថូសទី១ ១០:១៤

៧. ប្រហែលជាពិបាកណាស់ក្នុងការលះបង់ជំនឿនិងទំនៀមទម្លាប់ទាំងនេះចោល ។ ពួកបងប្អូនញាតិមិត្តទាំងឡាយប្រហែលខំពន្យល់បញ្ចុះបញ្ចូលមិនឲ្យអ្នកប្ដូរជំនឿរបស់អ្នក ។ ប៉ុន្តែរកផ្គាប់ព្រះហឫទ័យនៃព្រះគឺសំខាន់ជាងផ្គាប់ចិត្តរបស់មនុស្ស ។—សុភាសិត ២៩:២៥; ម៉ាថាយ ១០:៣៦, ៣៧



***បុណ្យណូអែលនិងបុណ្យអ៊ីស្ទើរ៍ គឺមកពីសាសនាក្លែងក្លាយ ជំនាន់បុរាណ***



***គ្មានមូលហេតុអ្វី ដែលយើងគួរថ្វាយបង្គំឬខ្លាច ដល់ពួកមនុស្សស្លាប់ឡើយ***